NSW STATEWIDE INFANT SCREENING – HEARING (SWISH) PROGRAM

# Why does my baby need a hearing check?



## ហេតុអ្វីបានជាកូនខ្ញុំត្រូវការជាចាំបាច់នូវការឆែកពិនិត្យមើលសោតវិញ្ញាណ?

នៅគ្រាដែលក្មេងចាប់ផ្តើមចេះនិយាយពាក្យមួយម៉ាត់ដំបូងរបស់គេនោះ គេបានស្តាប់ឮនូវភាសាដែលនិយាយជុំវិញមជ្ឈដ្ឋានរបស់គេ អស់ពេលប្រហែលជាមួយឆ្នាំមកហើយ។

ទារកម្នាក់ទៅ២នាក់ក្នុងចំណោមទារក១០០០នាក់ដែលកើតមកនឹងមានការបាត់បង់សោតវិញ្ញាណខ្លះរបស់គេ (ស្តាប់មិនសូវឮ)។

កម្មវិធីរបស់ NSW Statewide Infant Screening – Hearing (SWISH) មានបំណងរកមើលទារកទាំងឡាយណាដែលបាត់បង់សោតវិញ្ញាណខ្លះ ហើយចាប់ផ្តើមការណែនាំឲ្យទទួលនូវសេវាកម្ម(កិច្ចបំរើ)សមរម្យ ឲ្យបានរហ័សតាមលទ្ធភាព។

នឹងមានការស្នើផ្តល់ការឆែកពិនិត្យសុខភាពធម្មតាមួយចំនួនជាបន្តបន្ទាប់សំរាប់កូនលោកអ្នក នៅក្នុងរវាងពេល២-៣សប្តាហ៍ដំបូងក្រោយពីទារកប្រសូតមក។ ការឆែកពិនិត្យមើលសុខភាពទាំងនេះ នឹងរួមបញ្ចូលការពិនិត្យមួយដើម្បីរកមើលការបាត់បង់សោតវិញ្ញាណផងដែរ។ ការស្នើផ្តល់ការឆែកពិនិត្យរកមើលការបាត់បង់ សោតវិញ្ញាណនេះ នឹងប្រព្រឹត្តទៅភ្លាមៗទៅតាមលទ្ធភាពដែលអាចធ្វើទៅបានក្រោយពីទារកកើតរួច។ បើគ្មានលទ្ធភាពធ្វើនៅគ្រាដែលលោកអ្នកនិងកូនលោកអ្នកឋិតនៅក្នុងមន្ទីរពេទ្យទេ គេនឹងស្នើសុំការឆែកពិនិត្យសាឡើងវិញដើម្បីរកមើលការបាត់បង់សោតវិញ្ញាណ ចំពោះកូនលោកអ្នក ក្នុងលក្ខណៈជាអ្នកជម្ងឺមិនស្នាក់នៅក្នុងមន្ទីរពេទ្យ ឬក៏តាមទីកន្លែងសហគមន៍មូលដ្ឋានណាមួយ ឲ្យបានឆាប់ក្រោយពីលោកអ្នកចេញពីមន្ទីរពេទ្យ។

**តើការឆែកពិនិត្យកូនខ្ញុំតម្រូវឲ្យមានអ្វីខ្លះ?**

អ្នកធ្វើការឆែកពិនិត្យសោតវិញ្ញាណម្នាក់ដែលមានការហ្វឹកហាត់ត្រឹមត្រូវ នឹងធ្វើការឆែកពិនិត្យនេះ នៅពេលដែលកូនលោកអ្នកកំពុងគេង ឬក៏កំពុងតែសំរាកយ៉ាងស្ងៀមស្ងាត់។ អ្នកឆែកពិនិត្យនឹងដាក់បន្ទះប្រដាប់ស្រង់វិញ្ញាណដ៏ទន់តូចមួយ ទៅលើក្បាលកូនលោកអ្នក ហើយប្រើសម្លេងក្លិកក្លក់ស្រាលៗបញ្ចូលតាមប្រដាប់ដាក់ក្នុងត្រចៀកដ៏ទន់មួយ ទៅក្នុងត្រចៀកទាំងពីររបស់កូនលោកអ្នក ឬក៏តាមរយៈឧបករណ៍ពាក់ត្រចៀកសំរាប់ស្តាប់។

បន្ទះប្រដាប់ចាប់វិញ្ញាណនេះប្រើប្រព័ន្ធអេឡិចត្រូនិចថតយកនូវការឆ្លើយតបទាំងឡាយរបស់កូនលោកអ្នកទៅនឹងសូរសម្លេងទាំងពួង។



NSW HEALTH
Working as a Team

លោកអ្នកអាចបិតនៅជាមួយកូនលោកអ្នក នៅគ្រាដែលគេធ្វើការឆែកពិនិត្យនេះ។
ការឆែកពិនិត្យនេះ ជាទូទៅមិនធ្វើឲ្យកូនលោកអ្នកមានការភ័យភ្ញាក់ផ្អើលអ្វីទេ។
ការឆែកពិនិត្យអាចត្រូវការពេលពី១០ទៅ២០នាទីដើម្បីធ្វើកិច្ចការនេះឲ្យចប់សព្វគ្រប់។

**លទ្ធផលទាំងឡាយ**

លោកអ្នកនឹងបានទទួលលទ្ធផលទាំងឡាយភ្លាមៗ នៅគ្រាដែលគេបញ្ចប់ការឆែកពិនិត្យនេះ។ លទ្ធផលទាំងនោះនឹងត្រូវគេកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុសុខភាពផ្ទាល់របស់ទារក (សៀវភៅពណ៌ខៀវ)។

បើសិនជាលទ្ធផលបង្ហាញថា កូនលោកអ្នកត្រូវការការឆែកពិនិត្យមើលសាឡើងវិញនោះ គឺមិនមែនមានន័យថាកូនលោកអ្នកបាត់បង់សោតវិញ្ញាណឡើយ។  លទ្ធផលនេះអាចអាចបណ្ដាលមកពីមូលហេតុផ្សេងៗទៀត។

បណ្ដាមូលហេតុទូទៅបំផុត ដែលតម្រូវឲ្យមានការឆែកពិនិត្យមើលសាឡើងវិញនោះគឺ:

- កូនលោកអ្នកអាចប្រហែលជាមានការភ័យភ្ញាក់ផ្អើល នៅគ្រាដែលគេឆែកពិនិត្យ។
- មានទឹកឬក៏អ្វីរាំងស្ទះជាបណ្ដោះអាសន្ននៅក្នុងត្រចៀកក្រោយពីប្រសូតរួច។

សោតវិញ្ញាណអាចមិនបិតថេរដូចគ្នារហូត នៅក្នុងរយៈពេលណាមួយ។ ការឃ្លាំពិនិត្យមើលការលូតលាស់នៃការនិយាយនិងភាសារបស់កូនលោកអ្នក ក៏ដូចជាការឆ្លើយតបនៃកូនលោកអ្នកទៅនឹងសូរសម្លេងគឺជារឿងសំខាន់។

សូមមើលបញ្ជីរាយសកម្មភាព នៅក្នុងសៀវភៅកំណត់ហេតុសុខភាពផ្ទាល់របស់ទារក (សៀវភៅពណ៌ខៀវ)
ឬក៏បញ្ជីរាយសកម្មភាពនៅផ្នែកខាងក្រោយនៃសន្លឹកនេះ។

បើសិនជាលោកអ្នកមានការបារម្ភអំពីការលូតលាស់នៃសោតវិញ្ញាណ ឬការនិយាយ និងភាសារបស់កូនលោកអ្នកនៅពេលអនាគត សូមរៀបចំឲ្យមានការធ្វើតេស្តពិនិត្យមើលសោតវិញ្ញាណរបស់កូនលោកអ្នក។ វេជ្ជបណ្ឌិតលោកអ្នកអាចរៀបចំឲ្យមានការបញ្ជូនមួយទៅកាន់កន្លែងត្រឹមត្រូវសមរម្យ ដើម្បីធ្វើតេស្តពិនិត្យមើលសោតវិញ្ញាណរបស់កូនលោកអ្នក។

ការធ្វើតេស្តពិនិត្យមើលសោតវិញ្ញាណអាចធ្វើឡើងគ្រប់វ័យទាំងអស់។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង:

SWISH Information Line
Freecall 1800 551 175
NSW Department of Health
Tel. (02) 9391 9000
Fax. (02) 9391 9101
NSW HealthWeb site: www.health.nsw.gov.au

© NSW Health Department 2002

November 2002 SHPN (PHCC) 030086
Khmer

NSW HEALTH
Working as a Team

# បញ្ជីរាយសកម្មភាព

| | | |
|---|---|---|
| ចាប់ពីពេលកើតទៅដល់៣ខែ | ធ្វើប្រតិកម្មទៅនឹងសូរសម្លេងឮខ្លាំង | ○ |
| | មានសភាពស្ងប់ស្ងាត់ទៅនឹងសម្លេងឬសូរស័ព្ទដែលធ្លាប់ឮ | ○ |
| | ទារកចាប់ផ្តើមបញ្ចេញសម្លេងអ៊ុអ៊ី | ○ |
| | ឆ្លើយតបទៅនឹងសម្តី ដោយការសម្លឹងមើលមុខអ្នកនិយាយ | ○ |
| ៣ខែទៅ៦ខែ | បែរភ្នែកឬក្បាលទៅរកសូរសម្លេង | ○ |
| | ចាប់ផ្តើមបញ្ចេញសម្លេងដែលមានសូរស័ព្ទដូចជាសម្តី | ○ |
| | សើចហើយបញ្ចេញសម្លេងដើម្បីបង្ហាញនូវក្តីត្រេកត្រអាល និងការមិនសប្បាយចិត្ត | ○ |
| ៦ខែទៅ៩ខែ | បញ្ចេញសម្លេងទារក មានដូចជា 'ដាដា ' 'ម៉ាម៉ា' 'ប៉ាប៉ា' | ○ |
| | ស្រែក/បញ្ចេញសម្លេង ដើម្បីទាក់ទាញអារម្មណ៍ | ○ |
| | ជាញឹកញយនឹងឆ្លើយតបទៅនឹងពាក្យ'អត់ទេ' និងឈ្មោះរបស់ខ្លួន | ○ |
| | ឆ្លើយតបទៅនឹងការច្រៀងនិងភ្លេង | ○ |
| ៩ខែទៅ១២ខែ | ធ្វើត្រាប់នូវសម្លេងសម្តីរបស់អ្នកដទៃ | ○ |
| | យល់នូវពាក្យសាមញ្ញ មានដូចជា 'នំ' 'ឆ្កែ' និង 'ប៉ា' ជាដើម | ○ |
| | បែរក្បាលទៅរកសូរសម្លេងស្រាលៗ | ○ |
| | ចាប់ផ្តើមបញ្ចេញពាក្យដំបូង | ○ |
| ១២ខែទៅ១៨ខែ | ទំនងជាយល់នូវពាក្យថ្មីៗខ្លះជារៀងរាល់អាទិត្យ | ○ |
| | ធ្វើតាមការបង្គាត់និយាយសាមញ្ញ មានដូចជា 'យកនំ' ជាដើម | ○ |
| | ចង្អុលទៅកាន់មនុស្ស ផ្នែកនៃរាងកាយ ឬក៏ប្រដាប់ប្រដាលេង នៅពេលដែលគេសួរ | ○ |
| | រៀននិយាយហួរហែនូវពាក្យថ្មីៗ ប៉ុន្តែអាចមិនសូវច្បាស់ | ○ |
| ១៨ខែទៅ២៤ខែ | ស្តាប់រឿងឬក៏ចំរៀងសាមញ្ញ | ○ |
| | បញ្ចូលពាក្យ២ម៉ាត់ឬច្រើនជាងនេះ នៅក្នុងប្រយោគខ្លីៗ មានដូចជា 'យកនំទៀត ' | ○ |

ព័ត៌មានសំរាប់ការទាក់ទងក្នុងតំបន់:

November 2002 SHPN (PHCC) 030086
Khmer